00384599

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 02 / 10 / 2009
ម៉ោង (Time/Heure): 13:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

001/18-07-2007-ECCC/TC
E1/67

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 02 / 10 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះករណី "ឌុច"
# សាធារណៈ

## សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ
## ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៩ -ថ្ងៃជំនុំជម្រះទី ៦២

រៀបចំដោយ: ឌុច ផារី និង Natacha WEXELS-RISER

| |
|---|
| **កំណត់ហេតុអ្នកចូលរួម** |
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម ធូ មណី |
| ចៅក្រមបម្រុង៖ ចៅក្រម យូរ ឧត្តរា (បម្រុង) និង ចៅក្រម Claudia FENZ (បម្រុង) |
| ក្រឡាបញ្ជី៖ លោក Matteo Crippa, លោកស្រី សែ កុលវុឌ្ឍី,កញ្ញា Natacha Wexels-Riser, លោក ឌុច ផារី |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក William Smith លោក Vincent De Wilde D'estmael, លោក សេង ប៊ុនឃាង, លោក ប៉ាក ចន្ទលីណូ |
| ជនជាប់ចោទ៖ លោក កាំង ហ្គេចអ៊ាវ ហៅ ឌុច |



TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE E.C.C.C. C.E.T.C.

| |
|---|
| មេធាវីជនជាប់ចោទ៖ លោក ការ សាវុត្ថ, លោកស្រី Heleyn Unac, លោក ចាន់ រ៉ាវុធ, លោកស្រី Marie-Paule Canizares, លោក François Roux |
| មេធាវីដំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក Alain Werner, លោកស្រី Fabienne Trusses-Naprous, កញ្ញា ម៉ុច សុវណ្ណារី, កញ្ញា ទី ស្រីនណា, លោក ហុង គីមសួន លោក គង់ ពិសី |
| មេធាវីការពារសាក្សី៖ |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក កូវ កែវរតនៈ(អវត្តមាន), លោក សានរាដា(អវត្តមាន) លោក អ៊ុច អារុណ |
| ផ្សេងៗ៖ |

| **<u>ពេលវេលាទូទៅរបស់តុលាការ៖</u>** | | |
|---|---|---|
| ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០០៩ | ចាប់ផ្តើមម៉ោង៖ ៩.០៥ | បញ្ចប់ម៉ោង៖ ១៦.៤៥ |
| សម្រាកព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៥០ | បញ្ចប់ម៉ោង៖ ១១.១៥ |
| សម្រាក | ចាប់ផ្តើមម៉ោង៖ ១១.៥០ | បញ្ចប់ម៉ោង៖ ១៣.៣៥ |
| សម្រាកល្ងាច | ចាប់ផ្តើមម៉ោង៖ ១៤.៤៥ | បញ្ចប់ម៉ោង៖១៥.០៥ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ៥ ម៉ោង ១០ នាទី |

| **<u>កិច្ចដំណើរការនីតិវិធីផ្សេងទៀត</u>** | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
| ការជូនដំណឹងពីកាលវិភាគសវនាការសម្រាប់សប្តាហ៍ពីថ្ងៃទី ២៤ ដល់ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៩ និងសប្តាហ៍បន្ទាប់ | អង្គជំនុំជម្រះ | ៩.០៧ | ៩.១២ |
| ស្នើសុំការណែនាំពីអង្គជំនុំជម្រះទាក់ទង និងការកំណត់ពេលវេលាសម្រាប់សួរសំនួរដល់ជនជាប់ចោទ ទាក់ទងនឹងអត្តចរិតរបស់គាត់ និងស្នើសុំដាក់ឯកសារទាក់ទងនិងជម្លោះប្រដាប់អាវុធនៅចំពោះមុខអង្គជំនុំ | សហព្រះរាជអាជ្ញា | ៩.១២ | ៩.១៥ |

| | | | |
|---|---|---|---|
| ជម្រះ | | | |
| បញ្ហាទាក់ទងនិងដើមបណ្ដឹងរដ្ឋប្បវេណី | មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ២ ក្រុម១ និង ក្រុម ៣ | ៩.១៥ | ៩.២៥ |
| ស្ដាប់នូវសេចក្ដីថ្លែងការណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ នៅ | អង្គជំនុំជម្រះ និង ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ នៅ | ៩.២៦ | ១០.២៩ |
| សំនួរសួរដល់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ នៅ | សព្រះរាជអាជ្ញា | ១០.២៩ | ១០.៤៩ |
| សំនួរសួរដល់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ នៅ | មេធាវីការពារក្ដី | ១១.១៧ | ១១.៣៩ |
| សំនួររបស់ដើមបណ្ដឹងរដ្ឋប្បវេណីដល់ជនជាប់ចោទ និងសេចក្ដីសង្កេតរបស់ជនចាប់ចោទ ចំពោះសេចក្ដីថ្លែងការណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ នៅ | អង្គជំនុំជម្រះ | ១១.៤០ | ១១.៤៦ |
| អង្គជំនុំជម្រះប្រកាសនូវសេចក្ដីសម្រេចលើសំណើររបស់សហព្រះរាជអាជ្ញា | អង្គជំនុំជម្រះ | ១៣.៣៥ | ១៣.៣៨ |
| ស្ដាប់នូវសេចក្ដីថ្លែងការណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី ឈិន ណារី | ដើមបណ្ដឹងរដ្ឋប្បវេណី ក្រុម២ និង អង្គជំនុំជម្រះ | ១៣.៣៩ | ១៥.៤៧ |
| សំនួរសួរដល់ដើមបណ្ដឹងរដ្ឋប្បវេណី ឈិន ណារី ទាក់ទងនិងសេចក្ដីថ្លែងការណ៍របស់គាត់ | សហព្រះរាជអាជ្ញា | ១៥.៤៧ | ១៥.៥១ |
| ស្ដាប់នូវសេចក្ដីថ្លែងការណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី គួច មុនិន្ទ | ដើមបណ្ដឹងរដ្ឋប្បវេណី ក្រុម៤ និង អង្គជំនុំជម្រះ | ១៥.៥5 | ១៦.៣៨ |
| | | | |

**<u>សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**សំណើរបស់សហព្រះរាជអាជ្ញាទាក់ទងនិងកាលវិភាគសវនាការ**

- អង្គជំនុំជម្រះប្រកាសនូវកាលវិភាគសវនាការសម្រាប់សប្តាហ៍ពីថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៩ និង សប្តាហ៍បន្ទាប់ ។

- សហព្រះរាជអាជ្ញាស្នើសុំពេលវេលា ១ ម៉ោង ឬ ១ ម៉ោង ៣០ នាទី សម្រាប់សួរសំនួរដល់ជនជាប់ចោទទាក់ទងនិងអត្តចរិករបស់គាត់ ។ សហព្រះរាជអាជ្ញាក៏បានស្នើសុំពេលវេលា ១ ម៉ោង ៣០ នាទី សម្រាប់ដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះទាក់ទងនិងជំលោះប្រដាប់អាវុធ ។

**បញ្ហាទាក់ទងនិងដើមបណ្តឹងរដ្ឋប្បវេណី**

- មេធាវីដំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ បានជូនដំណឹងដល់អង្គជំនុំជម្រះថា ដៃគូរបស់ខ្លួនដែលជាមេធាវីបរទេសឈ្មោះ Silke Studzinsky មិនអាចចូលរួមសវនាការបានទេដោយសារគាត់កំពុងសម្រាកនៅមន្ទីរពេទ្យ ។ មេធាវីក៏បានជូនដំណឹងផងដែរថាកូនក្តីរបស់ខ្លួនឈ្មោះ **រស់ មេន** បានបោះបង់សិទ្ធិក្នុងការមកធ្វើសេចក្តីថ្លែងការនៅចំពោះមុខអង្គជំនុំជម្រះ តែរក្សាសិទ្ធិក្នុងការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដដែល ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ និង ក្រុម៣ ក៏បានជូនដំណឹងអំពីដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតផងដែរ ។

**ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ជុំ នៅ** (D25/16)

- តុលាការបន្តស្តាប់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ នៅ ។ សហព្រះរាជអាជ្ញា និងមេធាវីការពារក្តីតាំងសំនួរដល់ដើមបណ្តឹងរដ្ឋប្បវេណី ។ ជនជាប់ចោទធ្វើសេចក្តីសង្កេតចំពោះសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ។

**សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា**

- អង្គជំនុំជម្រះចេញសេចក្តីសម្រេច លើសំណើររបស់សហព្រះរាជអាជ្ញាដែលបានស្នើសុំពេលដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ (សូមមើលសេចក្តីសម្រេចខាងក្រោម)។

**ស្តាប់នូវសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឈិន ណាទី** (D25/2)



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C. C.E.T.C.

- អង្គជំនុំជម្រះស្តាប់នូវសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈិន ណាវី ។ សហព្រះរាជអាជ្ញាតាំងសំនួរដល់ដើមបណ្តឹងរដ្ឋប្បវេណី ។ មេធាវីការពារក្តី និងជនជាប់ចោទមិនមានសំនួរ ឬសេចក្តីសង្កេតទាក់ទងនិងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីទេ ។

**ស្តាប់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី តូច មនិន្ទ** (D25/14)

- អង្គជំនុំជម្រះស្តាប់នូវសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីតូច មនិន្ទ ។ សហព្រះរាជអាជ្ញា និងមេធាវីការពារក្តីមិនមានសំនួរសួរដល់ដើមបណ្តឹងរដ្ឋប្បវេណីទេ ។ ជនជាប់ជាប់មិនមានសេចក្តីសង្កេតចំពោះសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីទេ ។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧.៣**

| លេខយោង របស់អជសង | លេខយោងរបស់ កសចស | ឈ្មោះ/ការអធិប្បាយ | ចំណាត់ថ្នាក់ឯកសារ (សំងាត់បំផុត, សំងាត់ ឬសាធារណៈ) | កំណត់សម្គាល់ |
|---|---|---|---|---|
| E3/503/2 | D25/16/2 | ឧបសម្ព័ន្ធ ២៖ ប្រវត្តិរូបរបស់ អ្នកទោសឈ្មោះ ជុំ នៅ | សាធារណៈ | 00233371-00233371, 00211380-00211380, 00289729-00289729. មាននៅក្នុង E3 folder រួចហើយ |
| E68.5 | NA | ឧបសម្ព័ន្ធ ៥៖ អ្នកទោសដែលគេស្គាល់ថាឈ្មោះ ម៉ែន | សាធារណៈ | 00330944-00331191, ជាពិសេសត្រង់ទំព័រ 00331076. ឯកសារដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ |
| E68.14 | NA | ឧបសម្ព័ន្ធ ២៖ បញ្ជីឈ្មោះអ្នក | សាធារណៈ | 00331730-00331865, ជាពិសេស[illegible] |

| | | | | |
|---|---|---|---|---|
| | | ទោសមកពីអង្គភាព RAK | | 00331803. ឯកសារដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ |
| E3/505 | D25/2 | ពាក្យបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ឈិន ណារី | សាធារណៈ កោសលុប | 00152367-00152374, 00156825-00156833, 00280031-00280043. លុបព័ត៌មានទាក់ទងនិងបុគ្គល និងទំព័រចុងក្រោយ (អត្តសញ្ញាណប័ណ្ណ) |
| E3/506 | D36, Annex A | មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស.២១ | សាធារណៈ | 00080610-00081199, ជាពិសេសត្រង់ទំព័រ 00080640; 00158333-00158334, 00158331-00158332 |
| E3/507/1 | D25/14/1 | អត្តសញ្ញាណប័ណ្ណរបស់ តួច មុនិន្ទ | សម្ងាត់ | 00211332-00211332, 00231878-00231878 |
| E3/507 | D25/14 | ពាក្យបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ តួច មុនិន្ទ | សាធារណៈ កោសលុប | 00238408-00238414, 00211321-00211331 |
| E3/508 | D43, Annex A | បញ្ជីឈ្មោះអ្នកទោស ស.២១ | សាធារណៈ | 00161072-00161348, ជាពិសេសត្រង់ទំព័រ 00161084 និង 00161073; 00218021-00218212; 00218653-00218941; 00171429-00171798, ជាពិសេសត្រង់ទំព័រ 00171449. |
| E3/498 | D43, Annex B | បញ្ជីឈ្មោះអ្នកទោស | សាធារណៈ | 00209738-00210035; 00161349-00161491, ជាពិសេសត្រង់ទំព័រ 00161356 |
| E3/507/2 | D25/14/2 | ឧបសម្ព័ន្ធ ២៖ មជ្ឈមណ្ឌលឯកសារកម្ពុជា ទិន្នន័យជីវប្រវត្តិ | សាធារណៈ | 00239024-00239025, 00211333-00211333 |



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C. C.E.T.C.

| | | | | |
|---|---|---|---|---|
| | | របស់ ជា ខន | | |
| | | | | |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- **សេចក្តីសម្រេចកែប្រែកាលវិភាគសវនាការ**

អង្គជំនុំជម្រះសូមជូនដំណឹងដល់ភាគីឱ្យបានជ្រាបថា ដោយសារតែដំណើរការនីតិវិធីប្រព្រឹត្តទៅមានភាពឆាប់រហ័ស និងដោយសារតែមាននូវការបោះបង់សិទ្ធិក្នុងការធ្វើសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនក្នុងរយៈពេលពីរបីថ្ងៃកន្លងមកនេះ អង្គជំនុំជម្រះបានរៀបចំឡើងវិញនូវកាលវិភាគសវនាការសម្រាប់សប្តាហ៍បន្ទាប់ដូចខាងក្រោម៖

នៅថ្ងៃច័ន្ទ អង្គជំនុំជម្រះនឹងបន្តស្តាប់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ នៅ ហើយ បន្ទាប់នឹងស្តាប់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈិន ណារី , គួច មុន្និន និង រស់ មេន ។ បន្ទាប់ពីស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីខាងលើរួចហើយ អង្គជំនុំជម្រះនឹងសម្រាក ។

នៅព្រឹកថ្ងៃអង្គារ អង្គជំនុំជម្រះនឹងស្តាប់នូវសក្ខីកម្មរបស់អ្នកជំនាញ CP2/5 លើបញ្ហាទាក់ទងនិងពាក្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

នៅល្ងាចថ្ងៃអង្គារ អង្គជំនុំជម្រះនឹងស្តាប់នូវការជំទាស់របស់មេធាវីការពារក្តីចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងស្តាប់នូវការឆ្លើយតបពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះការជំទាស់នោះ ។ អង្គជំនុំជម្រះនឹងស្តាប់នូវការជំទាស់និងការឆ្លើយតបចំពោះការជំទាស់នេះ សម្រាប់រយៈពេលប្រហែលជា ២ ថ្ងៃ ។

បន្ទាប់មកអង្គជំនុំជម្រះនឹងចាប់ផ្តើមសួរសំនួរដល់ជនជាប់ចោទទាក់ទងនិងអត្តចារិករបស់គាត់ ។

នៅសប្តាហ៍បន្ទាប់ អង្គជំនុំជម្រះនឹងចាប់ផ្តើមស្តាប់សក្ខីកម្មរបស់អ្នកជំនាញនិងសាក្សីទាក់ទងនិងអត្តចារិករបស់ជនជាប់ចោទ។

អង្គជំនុំជម្រះរក្សាសិទ្ធិក្នុងការកែប្រែកាលវិភាគនេះ ហើយនឹងជម្រាបដល់ភាគីប្រសិនបើមានការផ្លាស់ប្តូរ



TRIAL CHAMBER · CHAMBRE DE PREMIÈRE INSTANCE · E.C.C.C · C.E.T.C

ប្រែកាលវិភាគតម្រូវឲ្យមាន ។

នឹងបន្តធ្វើបច្ចុប្បន្នភាពដល់ភាគី ប្រសិនបើការកែប្រែកម្មវិធីតម្រូវឲ្យមាន ។

- អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគីឲ្យបានជ្រាប អង្គជំនុំជម្រះយោងទៅលើសំណើរបស់សហព្រះរាជអាជ្ញាកាលពីព្រឹកមិញ ដែលបានស្នើសុំដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះផ្អែកតាមវិធាន៨៧ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ក្រោយពីបានបញ្ចប់នូវការស្តាប់សក្ខីកម្មរបស់សាក្សី និងអ្នកជំនាញទាក់ទងទៅនឹងអត្តចរិតរបស់ជនជាប់ចោទ អង្គជំនុំជម្រះនឹងកំណត់ពេលវេលាសម្រាប់ភាគីក្នុងការដាក់ឯកសារដែលមានរួចហើយនៅក្នុងសំណុំរឿងចំពោះអង្គជំនុំជម្រះអនុលោមតាមវិធាន៨៧.៣ ។ ប្រសិនបើភាគីណា មានបំណងដាក់ឯកសារថ្មីដោយផ្អែកតាមវិធាន៨៧.៤ សូមភាគីដាក់ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ។
- បង្គាប់ឲ្យនាំជនជាប់ចោទទៅមន្ទីរឃុំឃាំង និងនាំគាត់ត្រឡប់មកវិញនៅថ្ងៃអង្គារ ទី ២៥ ខែ សីហា ឆ្នាំ២០០៩ ។

<u>ដីកាសម្រាប់ការលើកវារកាលសវនាការ</u>

ការពន្យារពេលសវនាការ៖ សវនាការនឹងបន្តទៅថ្ងៃអង្គារ ទី ២៥ ខែ សីហា ឆ្នាំ ២០០៩ វេលាម៉ោង ៩.០០ ព្រឹក ។ NWR.

ភ្នំពេញ ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៩

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ឌុច ផារី** Natacha WEXELS-RISER